# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកំពង់ចាម**

លេខ: ០៨៧២/១៦ ស.ស.រ

ក្រសួងមុខងារសាធារណៈ
ចូល
លេខ: ៤៤៤០
មកដល់ថ្ងៃទី ០៦ ខែ ០៧ ឆ្នាំ ១៦
ម៉ោង ១០:០០

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តកំពង់ចាម

## អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៥១ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់នៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបការងារនៃការិយាលាល័យទាំងនោះ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

# សម្រេច

**ប្រការ ១**.-

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តកំពង់ចាម ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **លន់ លីមថៃ** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២-ឯកឧត្តម | **កៅ សុខអាន** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣-លោក | **ម៉ម គឿក** | ប្រធានមន្ទីរមុខងារសាធារណៈ | សមាជិកអចិន្ត្រៃយ៍ |
| ៤-លោក | **ហាន កុសល** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥-លោកស្រី | **លី ធីតា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោកស្រី | **កុល ធារិន** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៧-លោក លោកស្រី អភិបាល ក្រុង ស្រុក | | | សមាជិក |
| ៨-លោក លោកស្រី នាយកទីចាត់ការ និងអង្គភាពចំណុះសាលាខេត្ត | | | សមាជិក |
| ៩-លោក | **ថៃ ពិសិដ្ឋ** | អនុប្រធានមន្ទីរមុខងារសាធារណៈ | ជាមន្ត្រីបង្គោល |
| ១០-លោក | **សយ សារ៉េត** | ប្រធានការិយាល័យត្រួតពិនិត្យរដ្ឋបាលនិងបៀវត្ស | ជាមន្ត្រីបង្គោល |

**ប្រការ ២**.-

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តកំពង់ចាមមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង់ និងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធីយុទ្ធសាស្ត្រនិងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ខេត្ត។
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរវាងរដ្ឋបាលខេត្តជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោលបាយយុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ ។
- ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ជូនប្រធានស្ថាប័នសាមីជាប្រចាំ ។
- ត្រូវវាយការណ៍អំពីវឌ្ឍនភាព ឲ្យបានទៀងទាត់រៀងរាល់ត្រីមាស មកលេខាធិការរដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។
- ក្រុមការងាត្រូវផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈ មន្ត្រីបង្គោលក្នុងការស្វែងរក និងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាព ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំ របាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនូវសូចនាករដែលទាក់ទង់ទៅនិងវឌ្ឍនភាព នៃការអនុវត្ត កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត មកលេខាធិការរដ្ឋាន នៃគណៈកម្មាធិការ

កែទម្រង់រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ ។ ជាពិសេស មន្ត្រីបង្គោលត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ។

**ប្រការ ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយទៅនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយករដ្ឋបាលសាលាខេត្ត អភិបាល នៃគណៈអភិបាលក្រុង-ស្រុក នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះរដ្ឋបាលខេត្ត ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កំពង់ចាម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**លន់ លឹមថៃ**

<u>កន្លែងទទួល៖</u>

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

-លេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

-ក្រុមប្រឹក្សាខេត្តកំពង់ចាម

-ដូចប្រការ ៤

-ឯកសារ កាលប្បវត្តិ